# កិច្ចព្រមព្រៀងស្តីអំពីសហប្រតិបត្តិការទេសចរណ៍
## រវាង
## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង
## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ «ចាប់តាំងពីពេលនេះតទៅ ត្រូវបានចាត់ទុកថា "ជាភាគីពីរ"» ។

ដោយមានគោលបំណង ពង្រឹងទំនាក់ទំនងជាមិត្តភាពនិងការយោគយល់គ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ នៅក្នុងវិស័យទេសចរណ៍ ។

ភាគីទាំងពីរបានព្រមព្រៀងដូចតទៅ :

### មាត្រាទី ១

ភាគីទាំងពីរត្រូវបង្កើតឡើងនូវលក្ខណៈអនុគ្រោះ សំរាប់ការអភិវឌ្ឍន៍រយៈពេលយូរអង្វែង លើវិស័យទេសចរណ៍ ក្នុងទិសដៅជាផលប្រយោជន៍ទៅវិញទៅមករបស់ប្រទេសទាំងពីរ ។

### មាត្រាទី ២

ដោយអនុលោមទៅតាមច្បាប់នៃប្រទេសរៀងៗខ្លួនហើយនិងការប្រតិបត្តិការជាអន្តរជាតិ ភាគីទាំងពីរនឹងផ្តល់នូវការលើកទឹកចិត្ត តាមនីតិវិធីធម្មតា សំរាប់ពលរដ្ឋរបស់ខ្លួនដែលត្រូវធ្វើដំណើរក្នុងទិសដៅទេសចរណ៍ និងដែលប្រព្រឹត្តទៅរវាងប្រទេសទាំងពីរ ។

### មាត្រាទី ៣

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ នឹងចាត់តាំងអាជ្ញាធរទេសចរណ៍របស់ប្រទេសថៃ ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏នឹងចាត់តាំងក្រសួងទេសចរណ៍ធ្វើជាទីភ្នាក់ងារប្រតិបត្តិ នៅក្នុងការទទួលខុសត្រូវទៅលើគ្រប់បញ្ហា. ដែលពាក់ព័ន្ធទៅនិងការធ្វើអោយសំរេចនូវកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី៤

ភាគីទាំងពីរត្រូវសំរបសំរួលអាជ្ញាធរអនុវត្តដែលបានពោលពីខាងដើម របស់ភាគីនីមួយៗ ដើម្បីអោយបង្កើតការិយាល័យទេសចរណ៍តំណាងរបស់ខ្លួន ក្នុងប្រទេសម្ខាងទៀត ស្របតាមអនុភាពច្បាប់ ក្នុងប្រទេសដែលដាក់ការិយាល័យនោះ ។

## មាត្រាទី៥

ភាគីទាំងពីរត្រូវលើកទឹកចិត្តអាជ្ញាធរអនុវត្តរបស់ខ្លួន ក្នុងការធ្វើសហប្រតិបត្តិការកិច្ចការទេសចរណ៍ ស្របតាមអនុភាពនៃបញ្ញត្តិ និងបទបញ្ជា ក្នុងប្រទេសនីមួយៗនោះ ។

## មាត្រាទី៦

ភាគីទាំងពីរត្រូវលើកទឹកចិត្តអោយមានការផ្លាស់ប្តូរជំនាញ ចំពោះការរៀបចំ ការគ្រប់គ្រងនិងការដំណើរការកិច្ចការទេសចរណ៍ និងត្រូវជួយគ្នាទៅវិញទៅមកក្នុងការហ្វឹកហ្វឺនបុគ្គលិករបស់គេ ក្នុងវិស័យទេសចរណ៍ ។

## មាត្រាទី៧

កិច្ចព្រមព្រៀងនេះអាចត្រូវបានកែប្រែឬធ្វើវិសោធនកម្ម ដោយមានការព្រមព្រៀងជាលាយល័ក្ខអក្សររវាងភាគីទាំងពីរ ឬក៏អាចត្រូវបានបញ្ចប់ដោយភាគីណាមួយ ដោយមានការជូនដំណឹង៦ខែជាមុន ដោយលាយល័ក្ខអក្សរ ទៅអោយភាគីម្ខាងទៀត ។

## មាត្រាទី ៨

ប្រសិនបើមានវិវាទណាមួយកើតឡើងចេញពីការអនុវត្តន៏កិច្ចព្រមព្រៀងនេះ វិវាទនោះត្រូវបានដោះស្រាយតាមរយៈការចរចាររវាងភាគីទាំងពីរ ។

## មាត្រាទី ៩

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃដែលភាគីនីមួយៗ ទទួលបាននូវការជូនដំណឹងជាលាយល័ក្ខ-អក្សរពីភាគីម្ខាងទៀត ស្របតាមតំរូវការរបស់រដ្ឋធម្មនុញ្ញដើម្បីដាក់កិច្ចព្រមព្រៀងនោះអោយចូលជាធរមានហើយ ។

កិច្ចព្រមព្រៀងនេះ ត្រូវមានប្រសិទ្ធិភាពសំរាប់រយៈពេល៥ឆ្នាំ ហើយនឹងត្រូវបានបន្តទៅទៀតសំរាប់រយៈពេលស្មើគ្នា បើគ្មានភាគីណាមួយផ្តល់ការជូនដំណឹងជាលាយល័ក្ខអក្សរ ក្នុងបំណងបញ្ចប់កិច្ចព្រមព្រៀងនេះស្របតាម ខដែលមានចែងក្នុងមាត្រាទី៧ ។

ដើម្បីទុកជាសាក្សី ហត្ថលេខីខាងក្រោមនេះ បានទទួលសិទ្ធិយ៉ាងពេញច្បាប់ពីរដ្ឋាភិបាលរបស់ខ្លួន ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅទីក្រុងបាងកក ថ្ងៃទី២៩ ខែមីនា ឆ្នាំ ១៩៩៥ ជាភាសាខ្មែរ ថៃ និងអង់គ្លេស ។ អត្ថបទទាំងអស់មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខ្វែងគ្នារវាងអត្ថបទភាសាថៃ និង ខ្មែរ អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាគោល ។

| | |
|---|---|
| តំណាងអោយរដ្ឋាភិបាលនៃ<br>ព្រះរាជាណាចក្រកម្ពុជា | តំណាងអោយរដ្ឋាភិបាលនៃ<br>ព្រះរាជាណាចក្រថៃឡង់ដ៍ |
| វ៉េង សិរីវុឌ្ឍ<br>រដ្ឋមន្ត្រី ប្រចាំទីស្តីការនាយករដ្ឋមន្ត្រី<br>និងជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សារីត បូធិវីហុក<br>រដ្ឋមន្ត្រី ប្រចាំទីស្តីការនាយករដ្ឋមន្ត្រី<br>ប្រធានក្រុមប្រឹក្សាអភិបាល ក្រសួងទេសចរណ៍ |

## កិច្ចព្រមព្រៀងស្តីអំពីសហប្រតិបត្តិការទេសចរណ៍

## រវាង

## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង

## រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ «ចាប់តាំងពីពេលនេះតទៅ ត្រូវបានចាត់ទុកជា "ជាភាគីពីរ"» ។

ដោយមានគោលបំណង ពង្រឹងទំនាក់ទំនងជាមិត្តភាពនិងការយោគយល់គ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ នៅក្នុងវិស័យទេសចរណ៍ ។

ភាគីទាំងពីរបានព្រមព្រៀងដូចតទៅ :

### មាត្រាទី ១

ភាគីទាំងពីរត្រូវបង្កើតឡើងនូវលក្ខណៈអនុគ្រោះ សំរាប់ការអភិវឌ្ឍន៍រយៈពេលយូរអង្វែង លើវិស័យទេសចរណ៍ ក្នុងទិសដៅជាផលប្រយោជន៍ទៅវិញទៅមករបស់ប្រទេសទាំងពីរ ។

### មាត្រាទី ២

ដោយអនុលោមទៅតាមច្បាប់នៃប្រទេសរៀងៗខ្លួនហើយនិងការប្រតិបត្តិការជាអន្តរជាតិ ភាគីទាំងពីរនឹងផ្តល់នូវការលើកទឹកចិត្ត តាមនីតិវិធីធម្មតា សំរាប់ពលរដ្ឋរបស់ខ្លួនដែលត្រូវធ្វើដំណើរក្នុងទិសដៅទេសចរណ៍ និងដែលប្រព្រឹត្តទៅរវាងប្រទេសទាំងពីរ ។

### មាត្រាទី ៣

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ នឹងចាត់តាំងអាជ្ញាធរទេសចរណ៍របស់ប្រទេសថៃ ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏នឹងចាត់តាំងក្រសួងទេសចរណ៍ធ្វើជាទីភ្នាក់ងារប្រតិបត្តិ នៅក្នុងការទទួលខុសត្រូវទៅលើគ្រប់បញ្ហា ដែលពាក់ព័ន្ធទៅនិងការធ្វើអោយសំរេចនូវកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី៤

ភាគីទាំងពីរត្រូវសំរបសំរួលអាជ្ញាធរអនុវត្តដែលបានពោលពីខាងដើម របស់ភាគីនីមួយៗ ដើម្បីអោយបង្កើតការិយាល័យទេសចរណ៍តំណាងរបស់ខ្លួន ក្នុងប្រទេសម្ខាងទៀត ស្របតាមអនុភាពច្បាប់ ក្នុងប្រទេសដែលដាក់ការិយាល័យនោះ ។

## មាត្រាទី៥

ភាគីទាំងពីរត្រូវលើកទឹកចិត្តអាជ្ញាធរអនុវត្តរបស់ខ្លួន ក្នុងការធ្វើសហប្រតិបត្តិការកិច្ចការទេសចរណ៍ ស្របតាមអនុភាពនៃបញ្ញត្តិ និងបទបញ្ជា ក្នុងប្រទេសនីមួយៗនោះ ។

## មាត្រាទី៦

ភាគីទាំងពីរត្រូវលើកទឹកចិត្តអោយមានការផ្លាស់ប្តូរជំនាញ ចំពោះការរៀបចំ ការគ្រប់គ្រងនិងការដំណើរការកិច្ចការទេសចរណ៍ និងត្រូវជួយគ្នាទៅវិញទៅមកក្នុងការហ្វឹកហ្វឺនបុគ្គលិករបស់គេ ក្នុងវិស័យទេសចរណ៍ ។

## មាត្រាទី៧

កិច្ចព្រមព្រៀងនេះអាចត្រូវបានកែប្រែឬធ្វើវិសោធនកម្ម ដោយមានការព្រមព្រៀងជាលាយល័ក្ខអក្សររវាងភាគីទាំងពីរ ឬក៏អាចត្រូវបានបញ្ចប់ដោយភាគីណាមួយ ដោយមានការជូនដំណឹង៦ខែជាមុន ដោយលាយល័ក្ខអក្សរ ទៅអោយភាគីម្ខាងទៀត ។

## មាត្រាទី ៨

ប្រសិនបើមានវិវាទណាមួយកើតឡើងចេញពីការអនុវត្តន៏កិច្ចព្រមព្រៀងនេះ វិវាទនោះត្រូវបានដោះស្រាយតាមរយៈការចរចារវាងភាគីទាំងពីរ ។

## មាត្រាទី ៩

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅថ្ងៃដែលភាគីនីមួយៗ ទទួលបាននូវការជូនដំណឹងជាលាយល័ក្ខ-អក្សរពីភាគីម្ខាងទៀត ស្របតាមតំរូវការរបស់រដ្ឋធម្មនុញ្ញដើម្បីដាក់កិច្ចព្រមព្រៀងនោះអោយចូលជាធរមានហើយ ។

កិច្ចព្រមព្រៀងនេះ ត្រូវមានប្រសិទ្ធិភាពសំរាប់រយៈពេល៥ឆ្នាំ ហើយនឹងត្រូវបានបន្តទៅទៀតសំរាប់រយៈពេលស្មើគ្នា បើគ្មានភាគីណាមួយផ្តល់ការជូនដំណឹងជាលាយល័ក្ខអក្សរ ក្នុងបំណងបញ្ចប់កិច្ចព្រមព្រៀងនេះស្របតាម ខដែលមានចែងក្នុងមាត្រាទី៧ ។

ដើម្បីទុកជាសាក្សី ហត្ថលេខីខាងក្រោមនេះ បានទទួលសិទ្ធិយ៉ាងពេញច្បាប់ពីរដ្ឋាភិបាលរបស់ខ្លួន ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅទីក្រុងបាងកក ថ្ងៃទី២៩ ខែមីនា ឆ្នាំ ១៩៩៥ ជាភាសាខ្មែរ ថៃ និងអង់គ្លេស ។ អត្ថបទទាំងអស់មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខ្វែងគ្នារវាងអត្ថបទភាសាថៃ និង ខ្មែរ អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាគោល ។

| | |
|---|---|
| តំណាងអោយរដ្ឋាភិបាលនៃ | តំណាងអោយរដ្ឋាភិបាលនៃ |
| ព្រះរាជាណាចក្រកម្ពុជា | ព្រះរាជាណាចក្រថៃឡង់ដ៍ |
| វ៉េង សេរីវុឌ្ឍ | សាវិត បូធិវីហុក |
| រដ្ឋមន្ត្រី ប្រចាំទីស្តីការនាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រី ប្រចាំទីស្តីការនាយករដ្ឋមន្ត្រី |
| និងជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធានក្រុមប្រឹក្សាអភិបាល ក្រសួងទេសចរណ៍ |